# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៧. សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាការអន្តរក្រសួង
## ដើម្បីពិភាក្សាលើឯកសារទស្សនទានកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីពិភាក្សាការងារជាមួយភាគីថៃ លើឯកសារទស្សនទានពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍតាមបណ្តោយព្រំដែន មានសមាសភាព ដូចខាងក្រោមនេះ :

១- ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន

២- ឯកឧត្តម **វ៉ា គឹមហុង** ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែន អនុប្រធាន

៣- ឯកឧត្តម **ទឹម ឡើន** អគ្គលេខាធិការងរាជរដ្ឋាភិបាល សមាជិក

៤- ឯកឧត្តម **សក់ សេដ្ឋា** អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៥- ឯកឧត្តម **ខៀវ មុត** អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន សមាជិក

៦- ឯកឧត្តម **ម៉ៅ ធូរ៉ា** អគ្គនាយកបច្ចេកទេស ក្រសួងពាណិជ្ជកម្ម សមាជិក

| | | | | |
|---|---|---|---|---|
| ៧- ឯកឧត្តម | **សូ** | **ម៉ារ៉ា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេស ចរណ៍ | សមាជិក |
| ៨- ឧត្តមសេនីយ៍ឯក **ឈុំ** | | **សុខាន** | នាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ | សមាជិក |
| ៩- ឧត្តមសេនីយ៍ទោ **ចាន់** | | **អឿន** | ប្រធាននាយកដ្ឋាននគបាលព្រំដែន ក្រសួងមហាផ្ទៃ | សមាជិក |
| ១០- ឧត្តមសេនីយ៍ទោ **មៀច** | | **សុផានណា** | ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១១- លោក | **ហែម** | **សាវង** | ប្រធាននាយកដ្ឋានអាស៊ី ១ ក្រសួងការបរទេស | សមាជិក |
| ១២- បណ្ឌិត | **គុណ** | **ញឹម** | នាយករងទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ១៣- បណ្ឌិត | **ជា** | **វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤- លោក | **លី** | **ស៊ីវណ្ណា** | អនុប្រធាននាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**ប្រការ២ :** គណៈកម្មការអន្តរក្រសួងនេះ ត្រូវបង្កើតឡើងដើម្បីរៀបចំឯកសារទស្សនទាន និងពិភាក្សាការងារជាមួយភាគីថៃ ជុំវិញបញ្ហាពាក់ព័ន្ធនានា នៃទំនាក់ទំនងឆ្លងដែន សន្តិសុខ ការអភិវឌ្ឍតំបន់ព្រំដែនជាដើម ។

**ប្រការ៣ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ៤ :** គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋាននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយអាចប្រើប្រាស់ត្រារបស់ក្រសួងនេះ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៥ :** គណៈកម្មការអន្តរក្រសួងនេះ នឹងអស់សុពលភាព នៅពេលបញ្ចប់បេសកកម្មរបស់ខ្លួន ដូចមានចែងក្នុងប្រការ ២។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចំលងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ